ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

# សេចក្តីជូនដំណឹង
## ស្តីពី
## ការសហការផ្អាកការធ្វើដំណើរ ឬចល័តចេញពីកន្លែងស្នាក់នៅរបស់បងប្អូនពលករខ្មែរ ដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃឆ្ពោះមកព្រំដែនកម្ពុជា-ថៃ ចំនួន ១៤ថ្ងៃ

យោងវិធានការបិទខ្ទប់ភូមិសាស្ត្របណ្តាខេត្តមួយចំនួន ជាពិសេសខេត្តជាប់ព្រំដែនកម្ពុជា-ថៃ ដើម្បីទប់ស្កាត់ការឆ្លងរាលដាលក្នុងសហគមន៍នៃមេរោគកូវីដ-១៩ ប្រភេទដែលតា (Delta) និងការរឹតបន្តឹងវិធានការប្រយុទ្ធ និងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ សំដៅការពារសុខភាព និងអាយុជីវិតរបស់ប្រជាជន ក៏ដូចជាដើម្បីឈានឆ្ពោះទៅបើកដំណើរការប្រទេសជាតិឡើងវិញលើគ្រប់វិស័យ និងការរស់នៅជាមួយនឹងជំងឺកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មីនៅកម្ពុជា ក៏ដូចជាយោងលើវិធានការបិទខ្ទប់ការធ្វើដំណើរពីខេត្តមួយទៅខេត្តមួយ ដែលកំពុងស្ថិតនៅជាធរមាននៅក្នុងប្រទេសថៃ នោះក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់បងប្អូនពលករខ្មែរដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃដូចខាងក្រោម៖

១-កុំចល័តចេញពីកន្លែងស្នាក់នៅបច្ចុប្បន្នរបស់ខ្លួន ឆ្ពោះមកព្រំដែនកម្ពុជា-ថៃ ចំនួន ១៤ថ្ងៃ ចាប់ពីថ្ងៃទី៣០ ខែកក្កដា នេះ រហូតដល់ថ្ងៃទី១២ ខែសីហា ឆ្នាំ២០២១។ ប្រសិនបើមានធុរៈចាំបាច់ ឬចប់ការងារត្រូវវិលត្រឡប់មកប្រទេសកម្ពុជាវិញ សូមបងប្អូនមេត្តារង់ចាំរហូតដល់ក្រោយថ្ងៃទី១២ ខែសីហា។

២-ប្រសិនជាបងប្អូនធ្វើដំណើរមកព្រំដែនកម្ពុជា-ថៃ តាមមធ្យោបាយណាមួយក៏ដោយ គឺបងប្អូននឹងត្រូវគេតម្រូវឱ្យធ្វើដំណើរវិលត្រឡប់ទៅកន្លែងដើមវិញ។ ម្ចាស់រថយន្ត ឬមេខ្យល់ ដែលបំផុស ឬដឹកជញ្ជូនបងប្អូនពលករគឺល្មើសនឹងបម្រាមរបស់អាជ្ញាធរថៃ ហើយត្រូវប្រឈមនឹងការចាត់វិធានការតាមច្បាប់ផងដែរ។

៣-ក្នុងរយៈពេលស្នាក់នៅ និងធ្វើការនៅប្រទេសថៃ ប្រសិនជាបងប្អូនពលករមានបញ្ហានៅកន្លែងធ្វើការ ឬមានបញ្ហាជីវភាពលំបាកខ្លាំង គឺអាចទំនាក់ទំនងទៅស្ថានឯកអគ្គរាជទូតព្រះរាជាណាចក្រកម្ពុជាប្រចាំប្រទេសថៃ នៅរៀងរាល់ម៉ោងធ្វើការ (តាមរយៈទូរស័ព្ទលេខ 092 8050 561 ឬ 094 0925 905 ឬ 062 1413 009 ឬ 086 7999 957) ឬបងប្អូនអាចទំនាក់ទំនងទៅក្រុមការងារស្ម័គ្រចិត្តនៃ "ក្រុមការងារទឹកចិត្តពលករនៅថៃ" (តាមរយៈក្រុមតេឡេក្រាមឈ្មោះ "ជំនួយកូវីដ-១៩ នៅថៃ" https://t.me/helpkhmerinthailand) ដើម្បីស្ថានទូត ក៏ដូចជាក្រុមការងារស្ម័គ្រចិត្តពិនិត្យ និងខិតខំស្វែងរកដំណោះស្រាយជូនបងប្អូន។ បងប្អូនពលករ គួរខិតខំព្យាយាមទំនាក់ទំនងទៅលេខទូរស័ព្ទរបស់អាជ្ញាធរពាក់ព័ន្ធនៃប្រទេសថៃ ដូចមានក្នុងឧបសម្ព័ន្ធ១ នៃសេចក្តីជូនដំណឹងនេះផងដែរ។

៤-ចំពោះបងប្អូនពលករដែលសង្ស័យថាខ្លួនមានវិជ្ជមានកូវីដ-១៩ ឬមានវិជ្ជមានកូវីដ-១៩ កម្រិតស្រាល ហើយមិនទាន់ដឹងថាត្រូវទំនាក់ទំនងទៅផ្នែកណា គឺបងប្អូនអាចទទួលការពិគ្រោះយោបល់អំពីការព្យាបាលជំងឺកូវីដ-១៩ តាមរយៈ



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣) ៨៨ ៤៣ ៧៥ និងទូរសារ:(០២៣) ៨៨ ២៧ ៦៩

ក្រុមតេឡេក្រាមឈ្មោះ "ពិគ្រោះកូវីដ-១៩ នៅថៃ" https://t.me/consultcovidinthailand" ដែលមានក្រុមគ្រូពេទ្យសម្រាប់ផ្តល់ប្រឹក្សាយោបល់បឋម និងមានក្រុមស្ម័គ្រចិត្ត ដើម្បីផ្តល់កញ្ចប់ថ្នាំព្យាបាលជំងឺកូវីដ-១៩ កម្រិតស្រាល ជូនបងប្អូនក្នុងករណីចាំបាច់។ បងប្អូនពលករ គួរខិតខំព្យាយាមទំនាក់ទំនងទៅលេខទូរស័ព្ទរបស់មន្ទីរពេទ្យ ឬអាជ្ញាធរថៃ ដែលមានសមត្ថកិច្ចក្នុងការយកសំណាក និងព្យាបាលជំងឺកូវីដ-១៩ ដូចមាននៅក្នុងឧបសម្ព័ន្ធ២ នៃសេចក្តីជូនដំណឹងនេះ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមបងប្អូនពលករ ដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃទាំងអស់ជ្រាបជាព័ត៌មាន និងសូមកុំធ្វើដំណើរ ឬចល័តចេញពីកន្លែងស្នាក់នៅបច្ចុប្បន្នរបស់ខ្លួនឱ្យសោះ ដើម្បីចៀសវៀងការប្រឈមនឹងវិធានការច្បាប់នានា និងចៀសវាងការចម្លងជំងឺកូវីដ-១៩ ដល់មិត្តភក្តិ និងក្រុមគ្រួសារ។

ថ្ងៃសុក្រ ៦រោច ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២១

*ឧបសម្ព័ន្ធ១៖ លេខទូរស័ព្ទរបស់អាជ្ញាធរថៃ ដែលមានសមត្ថកិច្ចដោះស្រាយបញ្ហាការងារ និងជំនួយសង្គម*

## បងប្អូនពលករខ្មែរកំពុងធ្វើការនៅប្រទេសថៃដែលជួបបញ្ហាការងារ សូមទាក់ទង៖

### លេខទូរស័ព្ទទាក់ទងពលករបរទេស ដែលកំពុងជួបប្រទះបញ្ហាការងារ

- 099 9214 075
- 063 3761 177
- 086 1113 328
- 094 3362 615
- 087 7428 213

### លេខទូរស័ព្ទភ្នាក់ងារធានារ៉ាប់រង អង្គការ និងមូលនិធិផ្សេងៗ

| | |
|---|---|
| ការិយាល័យធានារ៉ាប់រងសង្គម | 1506 |
| ការិយាល័យសុខុមាលភាពជាតិ | 1330 |
| កាកបាទក្រហមថៃ | 1664 |
| មូលនិធិលើកកម្ពស់សិទ្ធិ និងគុណភាពជីវិតពលករ | 094 3362 615<br>061 2241 550 |
| មូលនិធិកញ្ចក់ | 094 878 664 |
| អង្គការយូនីសែស UNICEF | 023 569 499 |
| មូលនិធិរ៉ាក់ថៃ | 022 656 888 |

បងប្អូនពលករខ្មែរអាចស្វែងរកការពិគ្រោះយោបល់បន្ថែមអំពីការព្យាបាលជំងឺកូវីដ-១៩ តាមរយៈក្រុមតេឡេក្រាម https://t.me/tconsultcovidinthatiland ឬ QR Code

សូមចូលរួមអនុវត្តវិធានការណ៍
៣ការពារ៖ ពាក់ម៉ាស លាងដៃ និងរក្សាគម្លាត
៣កុំ ៖ កុំប៉ះពាល់គ្នា កុំទៅកន្លែងប្រមូលផ្តុំ និងកុំទៅកន្លែងបិទជិត

លេខទូរស័ព្ទស្ថានទូតព្រះរាជាណាចក្រកម្ពុជា ប្រចាំព្រះរាជាណាចក្រថៃ
092 8050 561 និង 094 0925 905
រៀបចំដោយ៖ ក្រុមការងារទឹកចិត្តពលករនៅថៃ

*ឧបសម្ព័ន្ធ២៖ លេខទូរស័ព្ទរបស់អាជ្ញាធរថៃ ដែលមានសមត្ថកិច្ចដោះស្រាយករណីកូវីដ-១៩*

## បងប្អូនពលករខ្មែរកំពុងធ្វើការនៅប្រទេសថៃដែលជួបបញ្ហាកូវីដ-១៩ សូមទាក់ទង៖




**លេខទូរស័ព្ទទទួលបញ្ហាកូវីដ-១៩**

- គណៈកម្មការគ្រប់គ្រងជំងឺឆ្លង **1422**
- មជ្ឈមណ្ឌលសង្គ្រោះបន្ទាន់ **1646**

**លេខទូរស័ព្ទភ្នាក់ងារសុខាភិបាលទទួលកូវីដ-១៩**

- នាយកដ្ឋានសេវាវេជ្ជសាស្ត្រផ្តល់ប្រឹក្សាអ្នកឆ្លងជំងឺកូវីដ-១៩ **1668**
- វិទ្យាស្ថានជាតិជំនាញវេជ្ជសាស្ត្រសង្គ្រោះបន្ទាន់ **1669**
- មជ្ឈមណ្ឌលទំនាក់ទំនងរាជរដ្ឋាភិបាលថៃ **1111**
- ភ្នាក់ងារថែទាំសុខភាពផ្លូវចិត្ត **1323**
- មជ្ឈមណ្ឌលប្រតិបត្តិការឆ្លើយតបពេលមានអាសន្នខាងសុខាភិបាលទីក្រុងបាងកក **094 386 0051**
- លេខសង្គ្រោះបន្ទាន់នាយកដ្ឋានអនាម័យ **02 245 4964**
- លេខសង្គ្រោះបន្ទាន់ទីក្រុងបាងកក **02 203 2393**
- កងយោធពលភូមិន្ទថៃ **Line ID: @covidtv5hd1** **02 2705 685-9**
  (ទទួលបន្ទុកអ្នកឆ្លងកូវីដ បន្លាស់ទីអ្នកជំងឺ ដឹកជញ្ជូនសព ២៤ម៉ោង ដោយឥតគិតថ្លៃ)

**សម្រាប់អ្នកនៅទីក្រុងបាងកក**

- ករណីសង្ស័យថា ឆ្លងកូវីដ-១៩ ឬជាអ្នកជំងឺកូវីដ-១៩ សូមទាក់ទងការិយាល័យទីក្រុងបាងកក

**094 386 0051** **082 001 6373** **022 454 964**

បងប្អូនពលករខ្មែរអាចស្វែងរកការពិគ្រោះយោបល់បន្ថែមអំពីការព្យាបាលជំងឺកូវីដ-១៩ តាមរយៈក្រុមតេឡេក្រាម https://t.me/tconsultcovidinthatiland ឬ QR Code

សូមចូលរួមអនុវត្តវិធានការណ៍

៣ការពារ៖ ពាក់ម៉ាស លាងដៃ និងរក្សាគម្លាត

៣កុំ ៖ កុំប៉ះពាល់គ្នា កុំទៅកន្លែងប្រមូលផ្តុំ និងកុំទៅកន្លែងបិទជិត

លេខទូរស័ព្ទស្ថានទូតព្រះរាជាណាចក្រកម្ពុជា ប្រចាំព្រះរាជាណាចក្រថៃ

092 8050 561 និង 094 0925 905

រៀបចំដោយ៖ ក្រុមការងារទឹកចិត្តពលករនៅថៃ